# សេចក្តីជូនដំណឹង
# ស្តីពី
# វិសោធនកម្មលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** ជាធនាគារពាណិជ្ជទីមួយក្នុងប្រទេសកម្ពុជា ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនមេត្តាជ្រាបថាៈ ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានទទួលស្គាល់ពីធនាគារជាតិ នៃ កម្ពុជា និងក្រសួងពាណិជ្ជកម្ម នូវលក្ខន្តិកៈដែលបានធ្វើវិសោធនកម្ម នូវចំណុចមួយចំនួនដូចខាងក្រោមៈ

១. ការផ្លាស់ប្តូរស្លាកសញ្ញារបស់ធនាគារ

២. ការបង្កើនដើមទុនចុះបញ្ជីរបស់ធនាគារ ដែលបានមកពីការបោះផ្សាយលក់ភាគហ៊ុនលើកដំបូងជាសាធារណៈចំនួន ៤.៣៤៤.៨៦៥ដុល្លារអាមេរិក ដូច្នេះដើមទុនចុះបញ្ជីសរុបរបស់ធនាគារកើនដល់ចំនួន ៤៣៣.១៦៣.០១៩ដុល្លារអាមេរិក ដូចមានជូនភ្ជាប់ក្នុងតារាងខាងក្រោមៈ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគហ៊ុនជាសាច់ប្រាក់ | | ភាគរយនៃកម្មសិទ្ធិ |
|---|---|---|---|---|
| | | រៀល | អាមេរិក | |
| AFT | 111,492,719 | 445,970,876,000 | 111,492,719 | 25.7392% |
| ASA | 107,204,547 | 428,818,188,000 | 107,204,547 | 24.7492% |
| SMBC | 78,259,310 | 313,037,240,000 | 78,259,310 | 18.0669% |
| COFIBRED | 52,530,223 | 210,120,892,000 | 52,530,223 | 12.1271% |
| ORIX | 52,530,223 | 210,120,892,000 | 52,530,223 | 12.1271% |
| TMF | 10,938,339 | 43,753,356,000 | 10,938,339 | 2.5252% |
| TFSF | 9,354,157 | 37,416,628,000 | 9,354,157 | 2.1595% |
| TSFF | 6,508,636 | 26,034,544,000 | 6,508,636 | 1.5026% |
| ភាគហ៊ុនិកសាធារណៈ | 4,344,865 | 17,379,460,000 | 4,344,865 | 1.0031% |
| **TOTAL** | **433,163,019** | **KHR 1,732,652,076,000** | **USD 433,163,019** | **100.00%** |

៣. - តែងតាំងលោក កាយ ឡូត ជាអភិបាលថ្មី (ចាត់តាំងដោយ ASA) បន្ទាប់ពីលោកស្រី Mirjam Janssen (ចាត់តាំងដោយ TMF, TFSF, TSFF) បានលាឈប់ពីតំណែងអភិបាលជាផ្លូវការ នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ ប្រសិទ្ធភាពនៃថ្ងៃ លោក កាយ ឡូត ចូលកាន់តំណែងគឺថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១។

- តែងតាំងលោក Albertus Bruggink (ចាត់តាំងដោយ ORIX) ជាអភិបាលថ្មី ជំនួសលោក Ryoji Nishimura (ចាត់តាំងដោយ ORIX) ដែលបានលាឈប់ពីតំណែងអភិបាលកាលពីថ្ងៃទី

២៩ ខែឧសភា ឆ្នាំ២០២០។ ប្រសិទ្ធភាពនៃថ្ងៃ លោក Albertus Bruggink ចូលកាន់តំណែងគឺ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។

ដូច្នេះសមាសភាពក្រុមប្រឹក្សាភិបាលថ្មី របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានដូចខាងក្រោម៖

| ល.រ | សមាសភាពក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|---|
| ១ | លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | បណ្ឌិត អ៊ិន ចាន់នី | អភិបាល |
| ៣ | លោក រ័ត្ន យូម៉េង | អភិបាល |
| ៤ | លោក Pieter Kooi | អភិបាលឯករាជ្យ |
| ៥ | លោក វ៉ាន់ ស៊ូអៀង | អភិបាលឯករាជ្យ |
| ៦ | លោក Ian S. Lydall | អភិបាលឯករាជ្យ |
| ៧ | លោក Kenichiro Mori | អភិបាល |
| ៨ | លោក Stéphane Mangiavacca | អភិបាល |
| ៩ | លោក កាយ ឡូត (តែងតាំងថ្មី) | អភិបាល |
| ១០ | លោក Albertus Bruggink (តែងតាំងថ្មី) | អភិបាល |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម វិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
**ធនាគារ អេស៊ីលីដា ភីអិលស៊ី**